# សោឡសកិច្ច ១៦



***សោឡសកិច្ច*** *គឺកិច្ច ១៦ យ៉ាង ដែលបុគ្គលត្រូវធ្វើ ដើម្បីឲ្យចិត្តបានរួចផុតចាកកិលេស ដោយធ្វើកិច្ចទាំង៤ ក្នុងអរិយសច្ច ៤ គឺ ៖*

១. **បរិញ្ញាកិច្ច** *កិច្ចដែលត្រូវកំណត់ដឹងនូវទុក្ខ ដែលជាទុក្ខអរិយសច្ច (ទុក្ខសច្ចៈ)។*

២. **បហានកិច្ច** *កិច្ចដែលត្រូវលះបង់នូវតណ្ហា ដែលជាទុក្ខសមុទយ-អរិយសច្ច* (*សមុទយសច្ចៈ*)។

៣. **សច្ឆិកិរិយាកិច្ច** *កិច្ចដែលត្រូវធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានដែលជាទុក្ខនិរោធអរិយសច្ច* (និរោធសច្ចៈ)។

៤. **ភាវនាកិច្ច** *កិច្ចដែលត្រូវធ្វើមគ្គឲ្យកើតឡើង ឲ្យចម្រើនឡើងដែលជាទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច* (មគ្គសច្ចៈ)។

*កិច្ចទាំង ៤ នេះ ប្រព្រឹត្តទៅក្នុងសោតាបត្តិមគ្គ សកទាគាមិមគ្គ អនាគាមិ-មគ្គ និងអរហត្តមគ្គ ឬថា សោតាបត្តិមគ្គ សកទាគាមិមគ្គ អនាគាមិមគ្គ និងអរហត្តមគ្គ ទាំងនេះ ក្នុងមគ្គនីមួយៗ មាន ឬធ្វើកិច្ច ៤ យ៉ាង ។*

**សោតាបត្តិមគ្គ មានកិច្ច ៤ គឺ**

១. **បរិញ្ញាកិច្ច** *កិច្ចដែលត្រូវកំណត់ដឹងនូវទុក្ខសច្ចៈ*

២. **បហានកិច្ច** *កិច្ចដែលត្រូវលះបង់នូវសមុទយសច្ចៈ*

៣. សច្ឆិកិរិយាកិច្ច *កិច្ចដែលត្រូវធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ចៈ*

៤. ភាវនាកិច្ច *កិច្ចត្រូវធ្វើឲ្យចម្រើនឡើងនូវមគ្គសច្ចៈ ។*

**សកទាគាមិមគ្គ មានកិច្ច ៤ គឺ**

១. បរិញ្ញាកិច្ច *កិច្ចដែលត្រូវកំណត់ដឹងនូវទុក្ខសច្ចៈ*

២. បហានកិច្ច *កិច្ចដែលត្រូវលះបង់នូវសមុទយសច្ចៈ*

៣. សច្ឆិកិរិយាកិច្ច *កិច្ចដែលត្រូវធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ចៈ*

៤. ភាវនាកិច្ច *កិច្ចត្រូវធ្វើឲ្យចម្រើនឡើងនូវមគ្គសច្ចៈ ។*

**អនាគាមិមគ្គ មានកិច្ច ៤ គឺ**

១. បរិញ្ញាកិច្ច *កិច្ចដែលត្រូវកំណត់ដឹងនូវទុក្ខសច្ចៈ*

២. បហានកិច្ច *កិច្ចដែលត្រូវលះបង់នូវសមុទយសច្ចៈ*

៣. សច្ឆិកិរិយាកិច្ច *កិច្ចដែលត្រូវធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ចៈ*

៤. ភាវនាកិច្ច *កិច្ចត្រូវធ្វើឲ្យចម្រើនឡើងនូវមគ្គសច្ចៈ ។*

**អរហត្តមគ្គ មានកិច្ច ៤ គឺ**

១. បរិញ្ញាកិច្ច *កិច្ចដែលត្រូវកំណត់ដឹងនូវទុក្ខសច្ចៈ*

២. បហានកិច្ច *កិច្ចដែលត្រូវលះបង់នូវសមុទយសច្ចៈ*

៣. សច្ឆិកិរិយាកិច្ច *កិច្ចដែលត្រូវធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ចៈ*

៤. ភាវនាកិច្ច *កិច្ចត្រូវធ្វើឲ្យចម្រើនឡើងនូវមគ្គសច្ចៈ ។*

*សរុបកិច្ចទាំងអស់ត្រូវជា ១៦ ហៅថា* ***សោឡសកិច្ច*** *។*

*សមដូចបទសាធកៈដែលមានក្នុងអដ្ឋកថាទាំងឡាយថា*

**កតំ ករណីយន្តិ** ចតូសុ សច្ចេសុ ចតូហិ មគ្គេហិ បរិញ្ញាបហាន-សច្ឆិកិរិយាភាវនាភិសមយវសេន សោឡសវិធម្បិ កិច្ចំ និដ្ឋាបិតន្តិ អត្ថោ។

*ពាក្យថា **មានកិច្ចបានធ្វើហើយ** សេចក្តីថា អធិប្បាយថា កិច្ចសូម្បីទាំង ១៦ បានឲ្យចប់ហើយ ដោយអំណាចនៃការត្រាស់ដឹង ដោយបរិញ្ញាកិច្ច បហានកិច្ច សច្ឆិកិរិយាកិច្ច ភាវនាកិច្ច ដោយមគ្គទាំង ៤ ក្នុង សច្ចៈទាំង ៤ ។*

## ឧទាហរណ៍ក្នុងព្រះបាលី

យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ។

*ពួកកុលបុត្រ ដែលចេញចាកផ្ទះហើយ ទៅបួសក្នុងភាពជាបុគ្គលមិនមានប្រយោជន៍ដោយផ្ទះ ដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ដោយបញ្ញារបស់ខ្លួនដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ បានសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង៤ មិនយូរប៉ុន្មាន ក៏បានដឹងច្បាស់ថា ជាតិកំណើតរបស់អាត្មា*

អញអស់ហើយ ព្រហ្មចរិយធម៌អញក៏បាននៅចប់ហើយ កិច្ចដែលត្រូវធ្វើ អញក៏បានធ្វើហើយ នឹងមានកិច្ចដទៃអំពីកិច្ចនេះតទៅទៀតឡើយ ។

បុគ្គល ៤ ពួក ព្រមព្រៀងដោយមគ្គ បុគ្គល ៣ ពួក ព្រមព្រៀងដោយផល ឈ្មោះថា សេក្ខៈ ។ ព្រះអរហន្ត ឈ្មោះថា អសេក្ខៈ ។ បុគ្គលក្រៅអំពីនេះ ឈ្មោះថា មិនមែនសេក្ខៈ ទាំងមិនមែនអសេក្ខៈ ។

## ឯកសារយោង

*-វិនយបិដក (អដ្ឋកថា) » បារាជិកកណ្ឌ-អដ្ឋកថា » វេរញ្ជកណ្ឌវណ្ណនា*

*-សុត្តបិដក (អដ្ឋកថា) » មជ្ឈិមនិកាយ (អដ្ឋកថា) » មូលបណ្ណាស-អដ្ឋកថា » មូលបរិយាយវគ្គោ*

*-សុត្តបិដក (អដ្ឋកថា) » សំយុត្តនិកាយ (អដ្ឋកថា) » សគាថាវគ្គ-អដ្ឋកថា » ព្រហ្មសំយុត្តំ*

*-សុត្តបិដក (អដ្ឋកថា) » អង្គុត្តរនិកាយ (អដ្ឋកថា) » ទុក-តិក-ចតុក្កនិបាត-អដ្ឋកថា » ព្រាហ្មណវគ្គោ*

*-សុត្តបិដក (អដ្ឋកថា) » ខុទ្ទកនិកាយ (អដ្ឋកថា) » ឧទាន-អដ្ឋកថា » នន្ទវគ្គោ*

*-សុត្តបិដក (អដ្ឋកថា) » ខុទ្ទកនិកាយ (អដ្ឋកថា) » សុត្តនិបាត-អដ្ឋកថា » ឧរគវគ្គោ*

*-សុត្តបិដក (អដ្ឋកថា) » ខុទ្ទកនិកាយ (អដ្ឋកថា) » ថេរគាថា-អដ្ឋកថា » ឯកកនិបាតោ*

*-សុត្តបិដក (អដ្ឋកថា) » ខុទ្ទកនិកាយ (អដ្ឋកថា) » ថេរីគាថា-អដ្ឋកថា » ឯកាទសកនិបាតោ*

*-អភិធម្មបិដក (អដ្ឋកថា) » បុគ្គលបញ្ញត្តិ-អដ្ឋកថា » និទ្ទេសវណ្ណនា*

*(ដោយខេមរ អភិធម្មាវតារ)*